មើលវីដេអូ ភាគទី ១២

# ១២ - ថីនចេតសិក (Sloth)

**ថីនតា = ថីនំ** សេចក្ដីរួញរា ឈ្មោះថា ថីនៈ ។

**ថីនៈ** នេះគប្បីឃើញថា ជាធម៌បៀតបៀនចិត្ត ឲ្យថយចាក អារម្មណ៍ ឬជាសភាវធម៌គ្របសង្កត់ចិត្ត ធ្វើឲ្យចិត្តថយ កម្លាំង ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់ថីនៈ

១ - អនុស្សាហនលក្ខណំ — មានការមិនឧស្សាហ៍ (ឬមិនអង់អាច) ជាលក្ខណៈ

២ - វីរិយវិនោទនរសំ — មានការកំចាត់បង់នូវការព្យាយាម ជាកិច្ច

៣ - សំសីទនបច្ចុប្បដ្ឋានំ — មានការរួញរានៃចិត្ត ជាអាការប្រាកដ

៤ - អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ

មានអយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែក ជាដើម ជាហេតុជិត។

# ១៣ - មិទ្ធចេតសិក (Torpor)

មិឌ្ឍនតា = មិទ្ធំ សេចក្ដីងោកងុយ ឈ្មោះថា មិទ្ធៈ។

មិទ្ធៈនេះ ជាសភាវៈធ្វើឲ្យចិត្តស្ពាក់ស្ពើរ ខ្ជិល ងងុយដេក ស្វាបជាដើម ។

# លក្ខណាទិចតុក្កៈរបស់មិទ្ធៈ

១ - អកម្មញ្ញតា លក្ខណំ | មានភាពមិនគួរដល់ការងារ (មិនរហ័សរហួន) ជាលក្ខណៈ

២ - ឱនហនរសំ | មានការបិទបាំងសហជាតធម៌ ជាកិច្ច

៣ - លីនតាបច្ចុប្បដ្ឋានំ | មានការរាថយ (រួញរា ងងុយ ងោកងក់) ជាអាការប្រាកដ

៤ - អរតិវិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ

មានអយោនិសោមនសិការៈ ក្នុងការមិនត្រេកអរ និងការរារែក ជាដើម ជាហេតុជិត។

**ថីនៈ** និង **មិទ្ធៈ** ចេតសិកទាំង ២ នេះ ប្រកបជាមួយ នឹងចិត្តដែលជាសសង្ខារិកៈ ៥ ដួង គឺ ក្នុងលោភមូលចិត្ត ៤ និងទោសមូលចិត្ត ១។ ចេតសិកទាំង ២ នេះ កើតរួមគ្នាជានិច្ច ដោយប្រៀប **ថីនៈ** ដូច អណ្តាតភ្លើង **មិទ្ធៈ** ដូច ពន្លឺ បើភ្លើងធំ ពន្លឺក៏ច្បាស់ បើភ្លើងតូច ពន្លឺក៏អន់ថយចុះ។

# ១៤ - វិចិកិច្ឆាចេតសិក (Doubt)

វិគតា ចិកិច្ឆាតិ = វិចិកិច្ឆា ឈ្មោះថា វិចិកិច្ឆា ព្រោះអត្ថថា មានសេចក្តីពិតក្នុងចិត្តទៅប្រាសហើយ បានដល់សេចក្តីសង្ស័យ ៨ យ៉ាង គឺ ៖

១ - សង្ស័យក្នុងព្រះពុទ្ធ

២ - សង្ស័យក្នុងព្រះធម៌

៣ - សង្ស័យក្នុងព្រះសង្ឃ

៤ - សង្ស័យក្នុងសិក្ខា

៥ - សង្ស័យក្នុងអតីតធម៌

៦ - សង្ស័យក្នុងអនាគតធម៌

៧ - សង្ស័យក្នុងអតីតធម៌ និងអនាគតធម៌

៨ - សង្ស័យក្នុងបដិច្ចសមុប្បាទ។

# លក្ខណាទិចតុក្កៈវិចិកិច្ឆា

១ - សំសយនលក្ខណា មានការសង្ស័យ ជាលក្ខណៈ

២ - កម្បនរសា មានការញាប់ញ័រ
(ឃ្លេងឃ្លោង ស្ទាក់ស្ទើរ) ជាកិច្ច

៣ - អវិនិច្ឆយបច្ចុប្បដ្ឋានា មានការវិនិច្ឆ័យមិនដាច់
ជាអាការប្រាកដ

អនេកសគាហ បច្ចុប្បដ្ឋានា វា ឬមានការកាន់យកចំណែក
តែម្យ៉ាងមិនបាន ជាអាការប្រាកដ

៤ - អយោនិសោមនសិការបទដ្ឋានា មានអយោនិសោមនសិការៈ
ជាហេតុជិត។

** គប្បីឃើញថា វិចិកិច្ឆានេះ ជាធម្មជាតិធ្វើនូវសេចក្ដីអន្តរាយដល់ការ
ប្រតិបត្តិត្រឹមត្រូវតាមធម៌។*

**អកុសលចេតសិក ១៤**

- **មោចតុក្កៈ ៤**
  - មោហចេតសិក ១
  - អហិរិកចេតសិក ១
  - អនោត្តប្បចេតសិក ១
  - ឧទ្ធច្ចចេតសិក ១
- **លោតិកៈ ៣**
  - លោភចេតសិក ១
  - ទិដ្ឋិចេតសិក ១
  - មានចេតសិក ១
- **ទោចតុក្កៈ ៤**
  - ទោសចេតសិក ១
  - ឥស្សាចេតសិក ១
  - មច្ឆរិយចេតសិក ១
  - កុក្កុច្ចចេតសិក ១
- **ថីទុកៈ ២**
  - ថីនចេតសិក ១
  - មិទ្ធចេតសិក ១
- **ឯកវិចិកិច្ឆា ១**
  - វិចិកិច្ឆាចេតសិក ១

## សរុបអកុសលចេតសិក ១៤ មាន ៥ ន័យ គឺ ៖

១ - មោចតុក្កចេតសិក ៤

២ - លោតិកចេតសិក ៣

៣ - ទោចតុក្កចេតសិក ៤

៤ - ថីទុកចេតសិក ២

៥ - វិចិកិច្ឆាចេតសិក ១

## ចប់ អកុសលចេតសិក